ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# ការរៀបចំទិន្នន័យដើមគ្រានៃការអភិវឌ្ឍ
# សមត្ថភាពរដ្ឋបាលក្រុង ស្រុក
# ខេត្តរតនគិរី

រតនគិរី, ថ្ងៃទី២១ ខែ ឧសភា ឆ្នាំ២០១២

# របាយការណ៍

## ស្តីពី

## ការរៀបចំទិន្នន័យដើមគ្រានៃការអភិវឌ្ឍ សមត្ថភាពរដ្ឋបាលក្រុង ស្រុក ខេត្តរតនគិរី

---

## ១. សេចក្តីផ្តើម

ក- ប្រវត្តិ:

ផែនការអនុវត្តរយៈពេល៣ឆ្នាំ(ផអ៣) គឺជាផែនការគាំទ្រការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់រដ្ឋាភិបាល ។ ផែនការនេះផ្តោតសំខាន់លើការរៀបចំឡើងនូវរចនាសម្ព័ន្ធប្រព័ន្ធគ្រប់គ្រង រួមជាមួយនឹងការបង្កើត និងការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឱ្យក្លាយជាស្ថាប័នសម្រាប់អភិបាលកិច្ចមូលដ្ឋាន និងកិច្ចអភិវឌ្ឍមូលដ្ឋាន ប្រកបដោយប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិក្នុងការអនុវត្តអាណត្តិរបស់ខ្លួន ដោយរួមបញ្ចូលទាំងការផ្តល់សេវាសាធារណៈស្របតាមគោលការណ៍នានានៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។ នាពេលបច្ចុប្បន្ននេះ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងសំខាន់ៗនៃរដ្ឋបាលថ្នាក់នេះ ត្រូវបានរៀបចំឡើងវិញ និងកំពុងត្រូវបានដាក់ឲ្យដំណើរការជាបណ្តើរៗក្នុងស្ថានភាពមួយដែលមានតម្រូវការយ៉ាងខ្លាំងផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស និងសមត្ថភាពស្ថាប័ន ។ អាស្រ័យហេតុនេះ កិច្ចអន្តរាគមន៍អភិវឌ្ឍសមត្ថភាព គឺជាកត្តាសត្យានុម័តក្នុងការកំណត់ពីភាពជោគជ័យនៃការងារកំណែទម្រង់របស់រដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ។

ក្នុងស្ថានភាពចំពោះមុខនេះ សមត្ថភាពរបស់រដ្ឋបាលក្រុង ស្រុក នូវមានកម្រិតនៅឡើយសម្រាប់ការអនុវត្តតួនាទី ភារកិច្ច ដែលបានកំណត់ក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានគិតិយុទ្ធនានាសម្រាប់អនុវត្តច្បាប់នេះ ។ ហេតុនេះ កិច្ចអន្តរាគមន៍លើការអភិវឌ្ឍសមត្ថភាពក្នុងក្របខណ្ឌអនុវត្តផអ៣ នឹងត្រូវរៀបចំឡើងយ៉ាងច្រើនជាបន្តបន្ទាប់ ។

ដើម្បីមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការសម្របសម្រួលការប្រមូល និងរៀបចំទិន្នន័យរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ បានត្រឹមត្រូវនោះ ក្រុមការងាររបស់លេខាធិការដ្ឋានគ.ជ.អ.ប និងក្រសួងមហាផ្ទៃ បានរៀបចំសៀវភៅណែនាំ និងបានរៀបចំការបណ្តុះបណ្តាលដល់គ្រូឧទ្ទេសថ្នាក់រាជធានី ខេត្តទាំង២៤ រយៈពេល២ថ្ងៃ ពីថ្ងៃទី៦-៧ ខែ មីនា ឆ្នាំ២០១២ នៅខេត្តកំពង់ចាម អំពីការរៀបចំទិន្នន័យដើមគ្រានៃការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ ដោយមានអ្នកចូលរួមមកពី២៤រាជធានី ខេត្ត ចំនួន៧២នាក់ ។ វគ្គនេះមានគោលបំណងសំខាន់ផ្តល់ការណែនាំដល់សិក្ខាកាមទាំងអស់មកពីរាជធានី ខេត្ត អំពីនីតិវិធីក្នុងការប្រមូលទិន្នន័យ ការរៀបចំរបាយការណ៍ ក៏ដូចជាការបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធកុំព្យូទ័រផងដែរ សំដៅធ្វើយ៉ាងណាឲ្យសិក្ខាកាមមកពីបណ្តារាជធានី ខេត្ត ទាំងអស់នោះ មានសមត្ថភាពអាចរៀបចំការបណ្តុះបណ្តាលបន្តដល់អ្នកពាក់ព័ន្ធនានា នៅតាមបណ្តារាជធានី ខេត្តរបស់ខ្លួនបាន ។

ថ្ងៃទី២៨-២៩ ខែ មីនា ឆ្នាំ២០១២ កន្លងទៅនេះ មន្ត្រីព័ត៌មានវិទ្យា និងទីប្រឹក្សាក្រុងស្រុក ខេត្តរតនគិរី បានចូលរួមវគ្គបណ្តុះបណ្តាលរួចមកហើយ អំពីការរៀបចំទិន្នន័យដើមគ្រានៃការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលក្រុង ស្រុក។ ក្រោយពីទទួលបានការបណ្តុះបណ្តាលមក ក្រុង ស្រុកទាំងអស់ បានរៀបចំក្រុមការងារដើម្បីទទួលខុសត្រូវក្នុងការសម្របសម្រួលដើម្បីរៀបចំទិន្នន័យនេះ។ មកដល់សប្តាហ៍ទី១ ខែឧសភា ឆ្នាំ២០១២ នេះ គ្រប់ក្រុង ស្រុកទាំង៩ ក្នុងខេត្តរតនគិរីបានបញ្ចប់រួចរាល់ហើយនូវការប្រមូល និងបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធកុំព្យូទ័រ(តាមរយៈគេហទំព័ររបស់គ.ជ.អ.ប) ។

**ខ- គោលបំណង:**

ការរៀបចំ និងការសម្របសម្រួលការប្រមូលទិន្នន័យនេះ មានគោលលបំណងសំខាន់ គឺដើម្បីជានាឲ្យមានទិន្នន័យមូលដ្ឋានអំពីសមត្ថភាពរបស់រដ្ឋបាលក្រុង ស្រុក (ស្ថាប័ន និងបុគ្គល) ដែលជាមូលដ្ឋានសម្រាប់កំណត់តម្រូវការ និងការវាស់វែងពីភាពរីកចម្រើននៃសមត្ថភាពរបស់រដ្ឋបាលក្រុង ស្រុក ក្នុងអំឡុងពេលអនុវត្ត និងនៅពេលបញ្ចប់ផអ៣ នៃកម្មវិធីជាតិ ។

**គ- វិធីសាស្រ្ត:**

ដើម្បីជានាឲ្យការប្រមូល និងការរៀបចំទិន្នន័យអាចដំណើរការទៅបានរលូនស្របតាមការណែនាំ និងកម្មវិធីដែលបានគ្រោងទុក ក្រុង ស្រុកទាំងអស់ក្នុងខេត្តរតនគិរី បានពិភាក្សាឯកភាពកំណត់ក្រុមការងារ តាមក្រុង ស្រុកនីមួយៗ ដែលរួមមានមន្ត្រីអភិវឌ្ឍន៍ថ្នាក់ខេត្ត ០១រូប មន្ត្រីព័ត៌មានវិទ្យាក្រុងស្រុក០១រូប និងទីប្រឹក្សាក្រុងស្រុក០១រូប ធ្វើជាអ្នកសម្របសម្រួលការងារទូទៅសម្រាប់ក្រុងស្រុកនីមួយៗ ។ ការប្រមូលទិន្នន័យ ត្រូវធ្វើឡើង៖

- ជាលក្ខណៈបុគ្គល ដែលរួមមាន ទាំងប្រធានក្រុមប្រឹក្សា សមាជិកក្រុមប្រឹក្សា អភិបាល អភិបាលរងនាយក នាយករងរដ្ឋបាល ប្រធាន អនុប្រធានការិយាល័យទាំងបី និងមន្ត្រីទាំងអស់ (ទម្រង់ទី១, ទី៨,៩,១០,១១,១២)។
- ជាលក្ខណៈក្រុមរួមគ្នាតាមអង្គភាពនីមួយៗ ដែលរួមមានក្រុមប្រឹក្សា គណៈអភិបាល ការិយាល័យចំណុះទាំងបីរបស់ក្រុងស្រុក ក្រុមការងារអភិវឌ្ឍសមត្ថភាពថ្នាក់ខេត្ត និងការិយាល័យច្រកចេញចូលតែមួយ (ទម្រង់ទី២,៣,៤,៥,៦,៧,១៣,១៤)។
- លទ្ធផលនៃការប្រមូលទិន្នន័យនេះ ត្រូវបានត្រួតពិនិត្យដោយទីប្រឹក្សាក្រុងស្រុក និងបញ្ចូលដោយមន្ត្រីព័ត៌មានវិទ្យាថ្នាក់ក្រុងស្រុក តាមប្រព័ន្ធកំព្យូទ័រ(គេហទំព័ររបស់ គ.ជ.អ.ប) ។
- ទម្រង់ទី៣ក និងទី៨ ត្រូវបានផ្តល់ជូនដល់អ្នកពាក់ព័ន្ធទាំងអស់ដើម្បីបំពេញ មុនពេលទទួលបានការបណ្តុះបណ្តាល/ណែនាំជាផ្លូវការ ។

## ២. លទ្ធផលនៃការសង្កេតទូទៅ

អ្នកសម្របសម្រួល បានសង្កេតជាទូទៅលើសកម្មភាព និងដំណើរការនានាក្នុងការប្រមូលទិន្នន័យនេះ ដោយក្នុងនោះផ្តោតសំខាន់លើ៖

ក. ការសង្កេតទូទៅ:

- **ការទទួលខុសត្រូវរបស់រដ្ឋបាលក្រុងស្រុក:** អភិបាល បានយកចិត្តទុកដាក់ និងគិតគូរខ្ពស់លើការងារនេះថាជាការងារអាទិភាព ដោយបានប្រជុំណែនាំ/ផ្សព្វផ្សាយដល់មន្ត្រីទាំងអស់អំពីការងារនេះ បានសម្រួលរកទីតាំង និងកំណត់ពេលវេលាសម្រាប់ការិយាល័យនីមួយៗត្រូវអនុវត្តបំពេញទិន្នន័យ។
- **ក្រុមការងារ:** បានដើរតួជួយកិច្ចការនានាដូចជាការជួយពន្យល់ណែនាំ ការពិនិត្យនិងកែសម្រួលទិន្នន័យក្នុងទម្រង់នានាដែលមន្ត្រីទាំងអស់បានបំពេញ និងការបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធកំព្យូទ័រ ដើម្បីធានាឲ្យកិច្ចការប្រមូលទិន្នន័យនេះមានប្រសិទ្ធភាព។
- **ការចូលរួមរបស់អ្នកពាក់ព័ន្ធនានា:** យើងពិនិត្យឃើញថា មន្ត្រីភាគច្រើនមិនបានមកតាមការអញ្ជើញ ឬណាត់របស់រដ្ឋបាលក្រុងស្រុកនោះទេ ធ្វើឲ្យការបំពេញទិន្នន័យត្រូវចំណាយពេលច្រើន ម៉្យាងវិញទៀតការបំពេញមិនមានលក្ខណៈសមស្រប/មិនត្រឹមត្រូវ(សម្រាប់សំនួរមួយចំនួន) ដែលតម្រូវឲ្យធ្វើការបង្ហាញ/ណែនាំឡើងវិញច្រើនលើកច្រើនសារ ។ មន្ត្រីភាគច្រើនបានបំពេញទិន្នន័យចូលក្នុងទម្រង់នៅក្នុងពេលណែនាំ តែមន្ត្រីមួយចំនួនត្រូវការពេលវេលាដើម្បីស្រាវជ្រាវរកឯកសារ និងព័ត៌មានពាក់ព័ន្ធនានានៅផ្ទះសិន ដែលប្រការនេះ វាទាមទារពេលវេលាច្រើនសម្រាប់បញ្ចប់ការបំពេញទិន្នន័យនេះ ។
- **ការទំនាក់ទំនង និងការផ្តល់ព័ត៌មាន:** ដោយមានការឯកភាព និងយល់ព្រមពីគណៈអភិបាល និងក្រុមប្រឹក្សា ក្រុមការងារក្រុង ស្រុក បានរៀបចំអញ្ជើញ ឬណាត់ជួបមន្ត្រីដើម្បីទទួលការណែនាំ និងផ្តល់ទម្រង់សម្រាប់បំពេញដោយបែកចែកពេលវេលាតាមស្ថាប័ននីមួយៗ ។ សម្រាប់មន្ត្រីដែលមិនអាចមកបំពេញទិន្នន័យនៅថ្នាក់ក្រុងស្រុកបាន ដោយសារមានជំងឺ ក្រុមការងារបានយកទម្រង់ផ្តល់ជូន និងណែនាំផ្ទាល់ដល់លំនៅដ្ឋានតែម្តង ។
- **ទម្រង់នានា:** ទម្រង់នានាត្រូវបានថតចំលង និងចែកជូនគ្រប់ការិយាល័យ និងអ្នកពាក់ព័ន្ធនានា។
- **ការទទួល ការពិនិត្យ និងការបញ្ចូលទិន្នន័យ:** ក្រោយពីបញ្ចប់ការពន្យល់ណែនាំ ពីក្រុមការងារ មន្ត្រីទាំងអស់ នៃក្រុងស្រុក បានដំណើរការបំពេញទិន្នន័យចូលក្នុងទម្រង់ដែលបានផ្តល់ជូន។ បន្ទាប់ពីបំពេញរួច មន្ត្រីទាំងអស់បានប្រគល់ឯកសារមកក្រុមការងារ។ ក្រុមការងារថ្នាក់ក្រុងស្រុក បានប្រជុំ

គ្នាដើម្បីពិនិត្យ និងបញ្ចូលក្នុងប្រព័ន្ធកំព្យូទ័រ ។ ក្នុងករណីមានការខ្វះចន្លោះ ឬការបំពេញមិនសមស្រប នោះក្រុមការងារ ត្រូវអញ្ជើញមន្ត្រីនោះមកណែនាំ និងបំពេញឡើងវិញ ។

**ខ. ចំណុចខ្លាំង និងចំណុចខ្វះខាតនានា**

| ចំណុចខ្លាំង | ចំណុចខ្វះខាត |
|---|---|
| - ការចាប់ផ្តើមបានល្អ ដោយមានប្រជុំណែនាំ មានការចូលរួមពីលោកប្រធានក្រុមប្រឹក្សា និងអភិបាលក្រុងស្រុក និងមន្ត្រីពាក់ព័ន្ធ ។<br>- ការរៀបចំបានល្អ ដោយមានឯកសារ(ទម្រង់)នានា ការបែកក្រុមសម្របសម្រួលតាមក្រុមគោលដៅនិងការិយាល័យនីមួយៗ។<br>- មានការយកចិត្តទុកដាក់ខ្ពស់ពីលោកអភិបាលក្រុងស្រុក ។<br>- មន្ត្រីទាំងអស់បានចូលរួមក្នុងកាបំពេញសំនួរនានាតាមទម្រង់ដែលបានផ្តល់ជូន។<br>- ទិន្នន័យទាំងអស់ ត្រូវបានវាយបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រ (តាមគេហទំព័រគ.ជ.អ.ប) ដោយមន្ត្រីព័ត៌មានវិទ្យាក្រុងស្រុក ក្រោមកិច្ចសហការគាំទ្រពីទីប្រឹក្សាក្រុងស្រុក និងមន្ត្រីព័ត៌មានវិទ្យាថ្នាក់ខេត្ត។<br>- មានការគាំទ្រ និងផ្តល់ការណែនាំជាប្រចាំពីក្រុមការងារថ្នាក់ខេត្ត ទាំងក្នុងដំណើរការប្រមូល និងការបញ្ចូលទិន្នន័យជាដើម ។ | - ការយល់ដឹងរបស់មន្ត្រីមានកម្រិតខុសគ្នា ជាក់ស្តែងមានមន្ត្រីប្រមាណ៣០%មិនសូវចេះអក្សរ អ្នកសម្របសម្រួលត្រូវព្យាយាមពន្យល់ណែនាំច្រើនលើកច្រើនសារ ។<br>- ពិតមែនតែមានការណែនាំ និងពន្យល់ពីគោលបំណងនៃការប្រមូលទិន្នន័យនេះក៏ដោយប៉ុន្តែជាក់ស្តែងនៅតែមានការខុសឆ្គងខ្លះៗក្នុងពេលបំពេញសំនួរនានា និង មានការស្ទាក់ស្ទើរក្នុងការផ្តល់ ឬការគូសចំលើយណាមួយដែលខ្លួនពេញចិត្ត ព្រោះខ្លាចប៉ះពាល់ដល់តួនាទី/តំណែងរបស់ខ្លួននាពេលបច្ចុប្បន្ន ។<br>- ចំពោះទម្រង់សំនួរដែលត្រូវបំពេញជាក្រុមរួមគ្នា មានអ្នកចូលរួមខ្លះមិនសូវមានមតិយោបល់អ្វីសោះ គឺភាគច្រើនគឺផ្តេកផ្តួលតែលើយោបល់របស់ប្រធាន<br>- ទោះបីមានការជូនដំណឹង និងកំណត់កាលបរិច្ឆេទច្បាស់លាស់ក៏ដោយ ក៏ប៉ុន្តែដំណើរការនៃការអនុវត្តបំពេញទិន្នន័យជាក់ស្តែង មិនបានប្រព្រឹត្តទៅដូចការគ្រោងទុកឡើយ គឺមានការយឺតយ៉ាវ។<br>- មន្ត្រីមួយចំនួន មិនមានវត្តមាននៅកន្លែងធ្វើការ ដែលក្រុមការងារត្រូវចំណាយពេលវេលាច្រើនថ្ងៃ ដើម្បីរង់ចាំ ។<br>- ថ្នាក់ដឹកនាំក្រុងស្រុកមួយចំនួន មិនសូវចាប់អារម្មណ៍ ឬអើពើ ឬជម្រុញលើកចូការនេះទេ |

| | |
|---|---|
| | ដោយចាត់ទុកថានេះជាការទទួលខុសត្រូវរបស់មន្ត្រីព័ត៌មានវិទ្យា និងទីប្រឹក្សាក្រុងស្រុក ។ |

## ៣. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

### ក. សេចក្តីសន្និដ្ឋាន:

យោងទៅតាមលទ្ធផលនៃដំណើរការប្រមូលទិន្នន័យ ការពិនិត្យ និងការបញ្ចូលទិន្នន័យ យើងអាចធ្វើការសន្និដ្ឋានបានថា ច្រើនជាងពាក់កណ្តាលនៃមន្ត្រីរបស់ក្រុងស្រុក ជាមន្ត្រីដែលមានអតីតការងារលើសពី៣ឆ្នាំ ហើយមិនសូវបានទទួលការបណ្តុះបណ្តាលជំនាញអ្វីច្រើនប៉ុន្មានទេពីមុនមក ។

ពិតមែនថារាល់សំនួរទាំងអស់ត្រូវបានបំពេញ តែទិន្នន័យទាំងនោះ មិនទាន់ប្រាកដថាត្រឹមត្រូវនោះទេ ព្រោះមានមន្ត្រីខ្លះហាក់មានភាពមិនច្បាស់លាស់ ឬស្ទាក់ស្ទើរក្នុងការសម្រេចចិត្តនៅឡើយ ។

ការិយាល័យទាំងបីរបស់ក្រុងស្រុកភាគច្រើនមិនមានមន្ត្រីគ្រប់គ្រាន់តាមតម្រូវការនៅឡើយ ។ ការិយាល័យខ្លះមានតែអនុប្រធានការិយាល័យ០១រូប និងមន្ត្រី០១រូបប៉ុណ្ណោះ(មិនមានប្រធាន និងបុគ្គលផ្សេងទៀត) ហើយការិយាល័យនៃក្រុងស្រុកខ្លះ មានតែមន្ត្រី២ទៅ៣រូប តែមិនមានប្រធាន ឬអនុប្រធានការិយាល័យនោះទេ ករណីនេះជាការប្រឈមមួយដែលមិនអាចរ៉ាប់រងការផ្តល់សេវាដល់មូលដ្ឋានបានគ្រប់ជ្រុងជ្រោយឡើយ ។

ក្រុងស្រុកភាគច្រើន មិនមានកន្លែងធ្វើការសមរម្យ /សមស្របទៅតាមការិយាល័យនីមួយៗ (ស្រុកខ្លះការិយាល័យពីរអង្គុយធ្វើការនៅក្នុងបន្ទប់តែមួយ)។ រីឯសម្ភារៈ/ឧបករណ៍ និងការផ្គត់ផ្គង់សេវានានាទៀតសោតក៏មិនមានគ្រប់គ្រាន់ផងដែរ ដូចជា ៖ តុ កៅអី ទូដាក់ឯកសារ កុំព្យូទ័រ ម៉ាស៊ីនថតចំលង និងការផ្គត់ផ្គង់អគ្គិសនី (គឺមានតែក្រុងបានលុង និង ស្រុកអូរជុំប៉ុណ្ណោះដែលមានភ្លើងអគ្គិសនីរដ្ឋប្រើប្រាស់ ដោយឡែក ៨ស្រុកផ្សេងទៀតមិនទាន់មាននៅឡើយ) ។

មានមន្ត្រីមិនច្រើនប៉ុន្មានដែលមានវត្តមានក្នុងការបំពេញការងាររបស់ខ្លួនជាប្រចាំ ក្រៅពីនោះ គឺមានតែឈ្មោះតែមិនមានមុខជាក់ស្តែងដើម្បីរ៉ាប់រងទទួលខុសត្រូវលើការងារទៅតាមតួនាទីរបស់ខ្លួន ។ តែផ្ទុយទៅវិញ មានមន្ត្រីខ្លះមកធ្វើការដែរតែមន្ត្រីទាំងនោះមិនមានលទ្ធភាព/សមត្ថភាពអាចបំពេញកិច្ចការដែលបានប្រគល់ជូន ដោយសារមូលដ្ឋានចំណេះដឹងទូទៅមានកម្រិតទាប(មិនសូវចេះអក្សរ) ។

### ខ. អនុសាសន៍:

យោងទៅតាមលទ្ធផលនៃដំណើរការប្រមូលទិន្នន័យ ក្រុមការងារ សូមផ្តល់អនុសាសន៍មួយចំនួនដូចខាងក្រោម៖

- ដើម្បីពង្រឹងសមត្ថភាពមន្ត្រីរបស់ក្រុងស្រុកឲ្យមានប្រសិទ្ធភាព គួររៀបចំឲ្យមានបុគ្គិលគ្រប់គ្រាន់នៅតាមការិយាល័យនីមួយៗ ជាពិសេសការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ និងការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ ។

- គួរមានកម្មវិធីលើកទឹកចិត្តដល់មន្ត្រីជាប្រចាំតាមរយៈ ការតម្លើងប្រាក់ខែ ការផ្តល់ឱកាសឲ្យទទួលបានការចូលរួមរៀនសូត្រវគ្គបណ្តុះបណ្តាលជំនាញរយៈពេលខ្លី ឬវែង (ដូចជាៈវគ្គការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល វគ្គកិច្ចការរដ្ឋបាល វគ្គការគ្រប់គ្រង និងចាត់ចែងថវិកាក្រុងស្រុក វគ្គការប្រាស្រ័យទាក់ទង) និងការផ្តល់ប័ណ្ណសរសើរ ឬប្រាក់រង្វាន់ជាដើម ។ល។

- មន្ត្រីទាំងអស់ គួរត្រូវបានផ្តល់ការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពជាប្រចាំលើជំនាញដែលខ្លួនទទួលខុសត្រូវ ។

- គួររៀបចំកន្លែងធ្វើការឲ្យបានសមរម្យតាមបទដ្ឋាន (មានអគារ មានបន្ទប់ធ្វើការតាមការិយាល័យនីមួយៗ មានសាលប្រជុំតូចឬ ធំ មានឃ្លាំងទុកដាក់សម្ភារៈ និងឯកសារ) ។

- គួរផ្តល់/ផ្គត់ផ្គង់សម្ភារៈ/ឧបករណ៍បរិក្ខា ឲ្យបានសមស្របតាមតម្រូវការជាក់ស្តែងនៃបន្ទុកការងាររបស់ការិយាល័យនីមួយៗ។

- មន្ត្រីគ្រប់រូបគួរផ្តោតការយកចិតទុកដាក់លើចំនុចសំខាន់ៗ ដូចជា ៖ ១)ការងារបច្ចេកទេសដែលរួមមានចំណេះដឹង និងជំនាញវិជ្ជាជីវៈដែលពាក់ព័ន្ធទៅនឹងក្របខ័ណ្ឌការងារ និង ២)គុណតម្លៃ/ក្រមសីលធម៌ការងារ ដែលរួមមានអត្តចរិតជាវិជ្ជមាន មានការប្តេជ្ញាចិត្ត និងការទទួលខុសត្រូវខ្ពស់ ការជឿជាក់លើខ្លួនឯង ចេះបត់បែន មានគំនិតឆ្នៃប្រឌិត ការគោរពគោលនយោបាយរបស់អង្គភាព រួមទាំងម៉ោងធ្វើការ ជាពិសេសប្រកាន់ខ្ជាប់នូវទស្សនៈបញ្ញាបយេនឌ័រ ។ ទោះបីជាយ៉ាងណាក៏ដោយ យន្តការនៃការលើកទឹកចិត្ត គឺមានសារៈសំខាន់ណាស់ ដើម្បីជម្រុញឲ្យមន្ត្រីធ្វើការប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

រតនគិរី,ថ្ងៃទី២១......ខែឧសភាឆ្នាំ២០១២
**រៀបចំដោយក្រុមការងារថ្នាក់ខេត្ត**

លេខៈ..០០៣/១២
បានឃើញ និងឯកភាព
រតនគិរី, ថ្ងៃទី..២២..ខែ..០៥..ឆ្នាំ២០១២
**នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្ស**

**យេន_សានិត**